# សវនាការលើការបង្ហាញឯកសារគន្លឹះ ត្រូវមេធាវីការពារក្តីធ្វើពហិការ

**ឌី សុជាតា**

នៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿងក្តី០០២ដំណាក់កាលទី២ ។ សវនាការនេះផ្តល់ឱកាសដល់ភាគីដាក់បង្ហាញឯកសារគន្លឹះនានាដែលខ្លួនយល់ថា មានការពាក់ព័ន្ធជាពិសេសទៅនឹងអង្គហេតុនីមួយៗសម្រាប់ការជំនុំជម្រះ ។ សវនាការនេះធ្វើឡើង ដោយពិចារណាថា ឯកសារភស្តុតាងទាំងអស់ ពុំមែនតែងតែត្រូវបានលើកយកមកបង្ហាញនៅក្នុងអំឡុងពេលនៃការសួរដេញដោលបុគ្គលដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ។ ភស្តុតាងមួយចំនួនត្រូវលើកឡើងនៅក្នុងសវនាការនេះ មានដូចជា វីដេអូ ការដកស្រង់អត្ថបទចេញពីសេចក្តីថ្លែងការណ៍ សៀវភៅ និងសារព័ត៌មាន និងកំណត់ហេតុស្តាប់ចម្លើយរបស់បុគ្គលមួយចំនួន ព្រមទាំងភស្តុតាងផ្សេងទៀត ។ សវនាការនេះ ក៏បានផ្តល់ឱកាសដល់សាធារណៈជនក្នុងការពិនិត្យមើលឯកសារ ដែលជាផ្នែកមួយនៃការជំនុំជម្រះឲ្យបានទូលំទូលាយនឹងប្រសើរផងដែរ ។ ទម្លាប់នៃការអនុវត្តសវនាការនេះបានធ្វើជាបន្តបន្ទាប់នៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ នៅពេលសវនាការលើអង្គហេតុនីមួយៗត្រូវបានបញ្ចប់ ហើយត្រូវកម្រិតត្រឹមតែការពិភាក្សាលើឯកសារ ដែលពាក់ព័ន្ធនឹងអង្គហេតុដែលបានជំនុំជម្រះនីមួយៗតែប៉ុណ្ណោះ ។ សវនាការលើការបង្ហាញឯកសារគន្លឹះ គឺខុសគ្នាពីនីតិវិធីនៃការទទួលយកឯកសារ ដោយសារ ភាគីអាចយោងទៅលើឯកសារ ដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ព្រមទាំងឯកសារទាំងឡាយ ដែលភាគីបានកំណត់ថា មានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ។ ភាគីពុំគប្បីពិភាក្សាពីភាពទទួលយកបាន ឬមិនទទួលយកបាននៃឯកសារឡើយ ។ ភាគីនានា និងជនជាប់ចោទត្រូវអនុញ្ញាតឲ្យផ្តល់យោបល់លើឯកសារ ដែលភាគីម្ខាងទៀតបានដាក់បង្ហាញប្រសិនបើភាគីចង់ធ្វើបែបនេះ ។ នៅក្នុងសវនាការនេះ អង្គជំនុំជម្រះបានស្នើដល់ភាគីត្រូវជៀសវាងការបង្ហាញឯកសារច្រំដែលដោយមិនត្រូវជ្រើសរើសឯកសារទាំងឡាយណា ដែលត្រូវបានពិភាក្សាពិស្តាក្នុងកិច្ចដំណើរការនីតិវិធីសវនាការពីមុនរួចហើយនោះទេ ។

ចំពោះសវនាការនាបង្ហាញឯកសារគន្លឹះនេះ ត្រូវធ្វើឡើងទាក់ទងនឹងប្រធានបទការដ្ឋានការងារទាំងបីរួមមានការដ្ឋានការងារទំនប់១មករា ការដ្ឋានការងារព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានការងារទំនប់ត្រពាំងថ្ម ។ ខណៈដែលភាគីសហព្រះរាជអាជ្ញា កំពុងបង្ហាញឯកសារគន្លឹះទាក់ទងនឹងការដ្ឋានការងារទំនប់១មករា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើដាក់ឯកសារកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានស្លាប់បាត់បង់ជីវិត និងសាក្សីដែលនៅរស់រានមានជីវិត ។ ប៉ុន្តែភាគីមេធាវីការពារក្តីអន្តរជាតិ

វិចទ័រ កូប៉េ បានលើកឡើងថា សវនាការដែលអនុញ្ញាតឲ្យដាក់បង្ហាញឯកសាររបៀបនេះ គឺមានលក្ខណៈជាសវនាការសន្និដ្ឋានបិទបញ្ចប់សំណុំរឿងទៅហើយ ។ ដូច្នេះការចូលរួមរបស់ខ្លួនពុំមានអត្ថន័យនោះឡើយ ។ បន្ទាប់មកមេធាវីការពារក្តីទាំងពីរក្រុម ដែលការពារក្តីឲ្យ នួន ជា និង ខៀវ សំផន ទាំងមេធាវីជាតិនិងអន្តរជាតិបានសម្រេចចិត្តដើរចេញពីបន្ទប់សវនាការ ។ ភ្លាមៗភាគីសហព្រះរាជអាជ្ញាបានលើកឡើងជាសំណួរថា តើការដកខ្លួនរបស់មេធាវីនៅពេលនេះអាចនឹងត្រឡប់មកការពារក្តីវិញ ឬក៏គួរតែតែងតាំងមេធាវីបម្រុងជំនួសភ្លាម? ចំណែកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពេជ អង្គ ដែលពុំបានធ្វើការកត់សម្គាល់ភ្លាមៗនៅពេលដែលអង្គជំនុំជម្រះប្រគល់វេទិការនោះ ប៉ុន្តែ បន្ទាប់ពីអង្គជំនុំជម្រះធ្វើការពិភាក្សាខ្លីមួយនៅក្នុងបន្ទប់សវនាការរួច បែរជាមេធាវី ពេជ អង្គ បានធ្វើការបញ្ជាក់ពីជំហរថា ក្រុមរបស់ខ្លួនមិនគាំទ្រឥរិយាបថរបស់មេធាវីការពារក្តីទេ ដោយសារមេធាវីការពារក្តីមានកាតព្វកិច្ចក្នុងការចូលរួមសវនាការដាក់បង្ហាញឯកសារគន្លឹះ មិនតែប៉ុណ្ណោះមេធាវីការពារក្តីអាចធ្វើសេចក្តីអត្ថាធិប្បាយ និងជំទាស់នៅពេលខាងមុខ ។ លោកបន្តថាការដកខ្លួនចេញពីសវនាការជាការមិនសមស្របឡើយ ។

ដោយហេតុថា អវត្តមានមេធាវីទាំងភាគីជាតិ និងអន្តរជាតិ ពុំអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបន្តសវនាការបាន ព្រោះជនជាប់ចោទពុំអាចទទួលការជំនុំជម្រះដោយពុំមានមេធាវីការពារខ្លួនបាន នោះ ប្រធានអង្គជំនុំជម្រះបានសម្រេចប្រកាសសម្រាកសវនាការក្នុងថ្ងៃនោះភ្លាម នៅមុនពេលសម្រាកអាហារថ្ងៃត្រង់ ដើម្បីដោះស្រាយបញ្ហាដែលកំពុងកើតមាន ។

ដោយផ្អែកលើគោលបំណងនៃការបើកសវនាការលើការដាក់បង្ហាញឯកសារគន្លឹះ គឺដើម្បីបម្រើដល់ផលប្រយោជន៍យុត្តិធម៌ ក៏ដូចជាដើម្បីឲ្យសាធារណៈជន បានយល់ដឹងប្រសើរជាងមុន ដូច្នេះការលើកយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីអាចបម្រើដល់គោលបំណងដ៏សំខាន់នេះ ។